ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តព្រះសីហនុ

<u>សំណុំរឿងព្រហ្មទណ្ឌ</u>

លេខ ៧៦ ចុះថ្ងៃទី ០៥

ខែ ឧសភា ឆ្នាំ ២០០៤

<u>សាលក្រម</u>

លេខ ៦៧ ចុះថ្ងៃទី ១៦

ខែ សីហា ឆ្នាំ ២០០៤

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តព្រះសីហនុ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសិហនុ នាថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញាស្តីទីអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ជាក្រឡាបញ្ជី

**<u>មេធាវី</u>**

លោក [redacted] មេធាវីការពារជនជាប់ចោទ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៦ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៤ ដែលមាន :

-ជនជាប់ចោទឈ្មោះ **អ ឈ** ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិប៉ៃនមាស ឃុំសំរោងទង ស្រុកត្រាំកក់ ខេត្តតាកែវ ទីលំនៅសព្វថ្ងៃក្រុម ៨ ភូមិត្រពាំងស្អុយ សង្កាត់អណ្តូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ របររកស៊ីធ្វើស្រែ ប្រពន្ធឈ្មោះ **ង ភ** មានកូន ០២នាក់ ឪពុកឈ្មោះ **ភ អ** (រ) ម្តាយឈ្មោះ **ស ច** (ស) ទោសពីមុន *គ្មាន* ។ ចាប់ខ្លួន និង ឃុំខ្លួនថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៤ និង ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន តាមដីកាសំរេចឱ្យជនល្មើសនៅក្រៅឃុំជាបណ្តោះអាសន្នលេខ ៩៩១ គ.ព.០៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ។

ត្រូវជាប់ចោទពីបទរំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិត្រពាំងស្អុយ សង្កាត់អណ្តូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ជនរងគ្រោះឈ្មោះ **ស ចន** ភេទស្រី អាយុ ២០ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី៨ ភូមិត្រពាំងស្អុយ សង្កាត់អណ្តូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ មុខរបរធ្វើស្រែ ។

សាលក្រមនេះចូលស្ថានភាពស្ថាពរកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៤

កំពង់សោម ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥

ក្រឡាបញ្ជី

[redacted]

CamScanner

-ឈ្មោះ **ឧ យ** ភេទស្រី អាយុ ៤៩ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី៨ ភូមិត្រពាំងស្នុយ សង្កាត់អណ្ដូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ មុខរបរធ្វើស្រែ ជាដើមបណ្ដឹងរដ្ឋប្បវេណី ។

-បានឃើញដីកាសំរេចកែប្រែបទល្មើសលេខ ៩៨៥ ត.ព.០៤ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាសំរេចឱ្យជនល្មើសនៅក្រៅឃុំបណ្ដោះអាសន្នលេខ ៩៩១ ត.ព.០៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៦៧ ដ.ស.ព ០៤ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០៤ របស់ព្រះរាជអាជ្ញាស្ដីទីអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១០៤៦ ត.ព.០៤ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

## ឯរឿងហេតុមានដូចតទៅ :

កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៤ វេលាម៉ោង ៧:០០យប់ ឈ្មោះ **ស ខន** ភេទស្រី មានទីលំនៅភូមិត្រពាំងស្នុយ សង្កាត់អណ្ដូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ បានទៅបត់ជើងនៅខាងក្រោយភូមិ ពេលទៅដល់ស្រាប់តែឈ្មោះ **អ ឈ** បានស្ទាក់ចាប់ដៃនាង ដោយនិយាយលួងលោមដើម្បីសុំស្នេហា តែនាងភ័យពេកក៏ស្រែកឱ្យគេជួយ រួចរត់ទៅផ្ទះ ហើយបានប្រាប់ឪពុកម្ដាយនាងទៀតផង ។ បន្ទាប់មកឪពុកម្ដាយនាងបានមកប្ដឹងសមត្ថកិច្ចតែម្ដងទៅ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ **អ ឈ** បានឆ្លើយថា : ខ្លួនធ្លាប់លួចស្រឡាញ់ជនរងគ្រោះជាយូរមកហើយ លុះដល់ថ្ងៃកើតហេតុខ្លួនបានឃើញជនរងគ្រោះឈ្មោះ **ខន** ទៅបត់ជើងនៅក្រោយភូមិ ពេលនោះខ្លួនទៅតាមពីក្រោយហើយបានចាប់ដៃនាងសួរនាំខ្លះៗក្នុងគោលបំណងសុំស្រឡាញ់ តែនាង **ខន** បានស្រែកហើយរត់មកផ្ទះ និង ទៅប្ដឹងប្រធានភូមិ ។ លុះព្រឹកឡើងទើបដោះស្រាយគ្នា តែមិនត្រូវរ៉ូវគ្នា ក៏បញ្ជូនសំណុំរឿងមកព្រហ្មទណ្ឌតែម្ដងទៅ ។ ក្រោយពេលកើតហេតុខ្លួនមិនបានរត់ទៅណាទេ ហើយខ្លួនក៏មិនបានចាប់រំលោភនារីរងគ្រោះដែរ ។ ជាង ០២ខែក្រោយមកខ្លួនក៏ត្រូវសមត្ថកិច្ចចាប់ខ្លួន ។

-ជនរងគ្រោះឈ្មោះ **ស ខន** បានឆ្លើយថា : ខ្លួនធ្លាប់ស្គាល់ជនជាប់ចោទនេះដែរ ព្រោះជាអ្នកភូមិផងរបងជាមួយគ្នា ហើយនៅយប់ថ្ងៃកើតហេតុថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៤ វេលាម៉ោងប្រហែល ៧:០០យប់ ខ្លួនបានទៅបត់ជើងនៅខាងក្រោយភូមិ ស្រាប់តែឈ្មោះ **អ ឈ** បានមកចាប់ដៃខ្លួន ពេលនោះខ្លួនភ័យពេកក៏ស្រែកឱ្យគេជួយ ហើយរត់ទៅផ្ទះដើម្បីប្រាប់ឪពុកម្ដាយ ហើយឪពុកម្ដាយបានទៅប្ដឹងសមត្ថកិច្ចឱ្យចាប់ខ្លួនជនជាប់ចោទតែម្ដងទៅ ។ ក្នុងរឿងនេះខ្លួនទុកសិទ្ធិឱ្យម្ដាយខ្លួនជាអ្នកទាមទារសំណងជម្ងឺចិត្តចុះ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **ឧ យ** បានឆ្លើយថា : ខ្លួនបានទទួលលុយសំណងជម្ងឺចិត្តចំនួន ៦០០ដុល្លាសហរដ្ឋអាមេរិក ( ប្រាំមួយរយគត់ ) ពីជនជាប់ចោទរួចរាល់ហើយដែរ ហេតុដូច្នេះខ្លួនឈប់ប្ដឹងហើយ និង សុំឱ្យតុលាការបន្ធូរបន្ថយទោសឱ្យជនជាប់ចោទដោយក្ដីអនុគ្រោះ ។

-សាក្សីឈ្មោះ **ម ត** បានឆ្លើយថា : ខ្លួនជាប្រពន្ធជនជាប់ចោទ ហើយនៅក្នុងរឿងនេះខ្លួនសុខចិត្តជួយ

CS CamScanner

ចេញសងថ្លៃសំណងជម្ងឺចិត្តទៅជនរងគ្រោះ ៦០០ដុល្លាសហរដ្ឋអាមេរិក (ប្រាំមួយរយគត់) និង សំណូមពរមកតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យប្ដីខ្លួនផងចុះ ។

-តាមការអានចម្លើយសាក្សីឈ្មោះ ស គរ និង ឈ្មោះ ស ឧ បានឆ្លើយថា : នៅថ្ងៃកើតហេតុខ្លួនទាំងពីរនាក់បានឃើញជនរងគ្រោះរត់មកផ្ទះដោយទឹកមុខស្លេកស្លាំង និង សក់ក្បាលរញ៉េរញ៉ៃ ខ្លួនក៏បានសួរថា មានរឿងអ្វីកើតឡើង ជនរងគ្រោះប្រាប់ថា ឈ្មោះ អ ល ចាប់រំលោភនាង ពេលនោះខ្លួនទាំងពីរនាក់បានទៅផ្ទះជនជាប់ចោទដើម្បីសាកសួរ ហើយជនជាប់ចោទនិយាយប្រាប់ខ្លួនទាំងពីរថា នឹងទទួលខុសត្រូវ ។ បន្ទាប់មកខ្លួនក៏បានទៅប្ដឹងនៅប្រធានភូមិ ទើបមានការដោះស្រាយរហូតដល់ពេលនេះ ។

-តាមការអានចម្លើយរបស់សាក្សីឈ្មោះ ខ ញ និង ឈ្មោះ ណ គន បានឆ្លើយថា : ជនជាប់ចោទ និងជនរងគ្រោះធ្លាប់មានទំនាក់ទំនងស្នេហាជាមួយគ្នាជាងមួយឆ្នាំមកហើយ ហើយខ្លួនធ្លាប់និយាយប្រាប់ប្រពន្ធជនជាប់ចោទច្រើនដងដែរ ។

-តាមការអានចម្លើយសាក្សីឈ្មោះ ឃ ស និងឈ្មោះ ៩ ៩ បានឆ្លើយថា : នៅព្រឹកបន្ទាប់ពីយប់កើតហេតុខ្លួនទាំងពីរបានទទួលដោះស្រាយរឿងដែល ស គរ និង ស ឧ បានមករាយការណ៍ពីយប់មិញថា ឈ្មោះ អ ល បានចាប់រំលោភឈ្មោះ ស ទន ឯការដោះស្រាយគ្នាមិនត្រូវគ្នា ខ្លួនទាំងពីរក៏ធ្វើរបាយការណ៍ទៅសង្កាត់តែម្ដងទៅ ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ អ ល ពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស់ ប្រព្រឹត្តនៅភូមិត្រពាំងស្គុយ សង្កាត់អណ្ដូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហេតុដូច្នេះសុំតុលាការសំរេចតាមច្បាប់ដោយអនុគ្រោះ ។

-មេធាវីបានធ្វើសេចក្ដីសន្និដ្ឋានការពារថា : ថ្វីត្បិតតែកូនក្ដីខ្លួនបានប្រព្រឹត្តក៏ពិតមែន ក៏ប៉ុន្តែកូនក្ដីខ្លួនបានធ្វើសំណងជម្ងឺចិត្តរួចហើយ ម្យ៉ាងទៀតចៅក្រមស៊ើបអង្កេតបានកែប្រែបទចោទប្រកាន់លើកូនក្ដីខ្លួនតាមដីកាសំរេចសុំកែប្រែបទល្មើសលេខ ៩៨៥ ត.ព.04 ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ហើយតំណាងអយ្យការក៏បានឯកភាពដែរ ហេតុដូច្នេះសុំតុលាការប្ដូរបទចោទប្រកាន់របស់តំណាងអយ្យការមកបទបៀតបៀនដល់កេរ្តិ៍ខ្មាសវិញ និង មេត្តាជួយបន្ធូរបន្ថយទោសឱ្យកូនក្ដីខ្លួនផង ។

-ឈ្មោះ អ ល ជាជនជាប់ចោទបាននិយាយសំដីចុងក្រោយថា : ខ្លួនសុំឱ្យតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ខ្លួនដឹងកំហុសហើយមានការសោកស្ដាយក្រោយជាខ្លាំង និង សន្យាថា លែងប្រព្រឹត្តអំពើដែលផ្ទុយនឹងច្បាប់ទៀតហើយ ។

-ក្រោយពីស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់ចម្លើយ និង ការអានចម្លើយសាក្សី

-ក្រោយពីស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្ដាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមផ្លូវច្បាប់ហើយ

CS CamScanner

## តុលាការខេត្តព្រះសីហនុ

## យល់ឃើញថា

-ពិតជាមានអំពើបៀតបៀនដល់កេរ្តិ៍ខ្មាស់ កើតឡើងកាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៤ នៅភូមិត្រពាំងស្គុយ សង្កាត់អណ្តូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ប្រាកដមែន ។

-តាមចម្លើយជនរងគ្រោះបានឆ្លើយនាពេលសវនាការថា ជនជាប់ចោទបានទៅស្ទាក់ចាប់ដៃខ្លួន ដើម្បីសុំស្នេហ៍តែមិនបានធ្វើអ្វីលើសពីនេះឡើយ ។

-តាមចម្លើយរបស់ជនជាប់ចោទបានសារភាពថា ខ្លួនពិតជាបានទៅស្ទាក់ចាប់ដៃជនរងគ្រោះ ដើម្បីសុំស្នេហ៍ ហើយពេលនោះជនរងគ្រោះក៏ស្រែក ហើយរត់ទៅផ្ទះបាត់ ហើយខ្លួនមិនបានធ្វើអ្វីទាក់ទងរឿងភេទឡើយ ។

-តាមចម្លើយរបស់សាក្សីសុទ្ធតែបានឆ្លើយប្រហាក់ប្រហែលគ្នាថា ជនជាប់ចោទ និង ជនរងគ្រោះធ្លាប់មានទំនាក់ទំនងស្នេហាជាមួយគ្នាជាយូរមកហើយ ។ នៅថ្ងៃកើតហេតុខ្លួនមិនមានវត្តមាននៅកន្លែងទេ ហើយក៏មិនដឹងថាជនជាប់ចោទបានធ្វើអ្វីទៅលើជនរងគ្រោះដែរ ។

-ដើមបណ្តឹងរដ្ឋប្បវេណីទាមទារប្រាក់សំណងជម្ងឺចិត្តចំនួន ៦០០ដុល្លាអាមេរិក ហើយជនជាប់ចោទបានបង់រួចរាល់ហើយដែរ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **អ ល** ពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស់ ប្រព្រឹត្តនៅភូមិត្រពាំងស្គុយ សង្កាត់អណ្តូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឡើងជាលើកទីមួយ ហើយពុំមានព្យសនកម្មធ្ងន់ធ្ងរដល់ជនរងគ្រោះ និងសង្គមឡើយ តុលាការគប្បីពិចារណាពីបញ្ហានេះ ។

-សេចក្តីសន្និដ្ឋានការពាររបស់មេធាវីមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិចារណាអំពីបញ្ហានេះ ។

## ហេតុដូច្នេះសំរេចសេចក្តី

១-កែប្រែបទល្មើសពីរំលោភសេពសន្ថវៈមកបៀតបៀនដល់កេរ្តិ៍ខ្មាសវិញ តាមបញ្ញត្តិមាត្រា ១០៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣ ។

២-ផ្តន្ទាទោសឈ្មោះ **ះ ល** ភេទប្រុស អាយុ ៣៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ ( មួយ ) ឆ្នាំ តែទោសនេះត្រូវព្យួរកំណត់រយៈពេលសាកល្បងចំនួន ០៥ឆ្នាំ គិតចាប់តាំងពីថ្ងៃសាលក្រមនេះចូលជា ស្ថាពរ ។

ពីបទបៀតបៀនដល់កេរ្តិ៍ខ្មាស់ ប្រព្រឹត្តនៅភូមិត្រពាំងស្គុយ សង្កាត់អណ្តូងថ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ និង មាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-ឱ្យឈ្មោះ **ះ ល** សងទៅឈ្មោះ **ស ទន** នូវសំណងអន្តរាយ និង សំណងជម្ងឺចិត្តចំនួន ៦០០ដុល្លា ( ប្រាំមួយរយដុល្លាសហរដ្ឋអាមេរិក ) តាមការព្រមព្រៀងគ្នានៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ។

CS CamScanner

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជំរះ

[redacted]

CS CamScanner